**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ ស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល



https://www.moj.gov.kh/kh/law-regular

- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យភាពសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១ ._**

ត្រូវបានទទួលស្គាល់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាលប្រចាំឆ្នាំ២០២៣ តាមលំដាប់ចំណាត់ថ្នាក់ ដូចខាងក្រោម៖

**១. វិស័យអប់រំ**

**១.១ អនុវិទ្យាល័យ**

| អង្គភាព | រាជធានី ខេត្ត | ចំណាត់ថ្នាក់ |
|---|---|---|
| អនុវិទ្យាល័យភ្នំយ៉ាត | ប៉ៃលិន | លេខ១ |
| អនុវិទ្យាល័យមិត្តភាពខ្មែរ-ជប៉ុន ព្រះឥន្ទកោសា | សៀមរាប | លេខ២ |
| អនុវិទ្យាល័យសង្គមថ្មី | ព្រះវិហារ | លេខ៣ |
| អនុវិទ្យាល័យពោធិ៍សាត់ | ពោធិ៍សាត់ | លេខ៤ |
| អនុវិទ្យាល័យទីរួមខេត្ត | កំពង់ស្ពឺ | លេខ៥ |
| អនុវិទ្យាល័យអន្លង់អក | កំពង់ចាម | លេខ៦ |
| អនុវិទ្យាល័យទួលថ្ម | កំពង់ចាម | លេខ៧ |
| អនុវិទ្យាល័យលង្វែក | កំពង់ឆ្នាំង | លេខ៨ |
| អនុវិទ្យាល័យហ៊ុន សែនពោធិ៍ចិនតុង | ភ្នំពេញ | លេខ៩ |
| អនុវិទ្យាល័យបាក់អំរែក | បាត់ដំបង | លេខ១០ |

**១.២ សាលាបឋមសិក្សា**

| អង្គភាព | រាជធានី ខេត្ត | ចំណាត់ថ្នាក់ |
|---|---|---|
| សាលាបឋមសិក្សាស្វាយជ្រំ | ស្វាយរៀង | លេខ១ ស្មួន |
| សាលាបឋមសិក្សា សម្តេចជា ស៊ីម | បាត់ដំបង | លេខ១ ស្មួន |
| សាលាបឋមសិក្សាវត្តបូព៌ | សៀមរាប | លេខ៣ |
| សាលាបឋមសិក្សាចតុមុខ | ភ្នំពេញ | លេខ៤ |
| សាលាបឋមសិក្សាគិរីសុវណ្ណវង្ស | កំពង់ឆ្នាំង | លេខ៥ |
| សាលាបឋមសិក្សាក្រវ៉ាន់ | សៀមរាប | លេខ៦ |
| សាលាបឋមសិក្សាវត្តចែង | បាត់ដំបង | លេខ៧ |



https://www.moj.gov.kh/kh/law-regular

| | | |
|---|---|---|
| សាលាបឋមសិក្សាអនុវត្ត ហ៊ុន សែន អាចារ្យលាក់ | កំពង់ធំ | លេខ៨ |
| សាលាបឋមសិក្សាសំរោង | ឧត្ដរមានជ័យ | លេខ៩ |
| សាលាបឋមសិក្សាអង្គជុំ | កំពត | លេខ១០ |

**២. វិស័យសុខាភិបាល**

| **អង្គភាព** | **រាជធានី ខេត្ត** | **ចំណាត់ថ្នាក់** |
|---|---|---|
| មណ្ឌលសុខភាព សំរោង | ពោធិ៍សាត់ | លេខ១ |
| មណ្ឌលសុខភាព គោកចក | សៀមរាប | លេខ២ |
| មណ្ឌលសុខភាព បឹងបត់កណ្ដាល | ពោធិ៍សាត់ | លេខ៣ |
| មណ្ឌលសុខភាព ព្រៃញ្ញៅ | ព្រៃវែង | លេខ៤ |
| មណ្ឌលសុខភាព ពេជចង្វារ | កំពង់ឆ្នាំង | លេខ៥ |
| មណ្ឌលសុខភាព ថ្មគ្រែ | ក្រចេះ | លេខ៦ |
| មណ្ឌលសុខភាព អង្គភ្នំតូច | កំពត | លេខ៧ |
| មណ្ឌលសុខភាព តានី | កំពត | លេខ៨ |
| មណ្ឌលសុខភាព ស្ដី | កំពង់ចាម | លេខ៩ |
| មណ្ឌលសុខភាព បុស្សូរ | បន្ទាយមានជ័យ | លេខ១០ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១០ កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular